GRANDIS
TIMBER Limited
Commercial Reforestation

# សូមគោរពជូន
# លោកប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**កម្មវត្ថុ** ៖របាយការណ៍ឆមាសទី២ ឆ្នាំ២០២១ (ខែមិថុនា ដល់ ធ្នូ ឆ្នាំ២០២១) ស្តីពីអង្កេតតាមដានបរិស្ថាន និងសង្គម សម្រាប់គម្រោងដាំដើមម៉ៃសាក់របស់ក្រុមហ៊ុន ហ្គ្រេនឌីស ធីមបើរ អិលធីឌី ស្ថិតនៅឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច និងឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

**យោង** ៖កិច្ចសន្យាការពារបរិស្ថាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន **លោកប្រធាននាយកដ្ឋាន** មេត្តាជ្រាបថា ក្នុងរយៈពេល០៦ខែ (ខែមិថុនា-ខែធ្នូ ឆ្នាំ២០២១) ក្រុមហ៊ុនហ្គ្រេនឌីស ធីមបើរ អិលធីឌី បានដំណើរការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន អនុលោមតាមខ្លឹមសារនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ និងកិច្ចសន្យាការពារបរិស្ថាន និងសង្គម ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## ១. សេចក្តីផ្តើម

ក្រុមហ៊ុនហ្គ្រេនឌីស ធីមបើរ អិលធីឌី ជាក្រុមហ៊ុនបរទេសទទួលបានថវិកាវិនិយោគពីប្រទេសដាណាម៉ាក់បានទទួលសិទ្ធិស្របច្បាប់សម្រាប់ការវិនិយោគសម្បទានដីសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលកម្ពុជាតាមកិច្ចសន្យា ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ និងកិច្ចសន្យាកែតម្រូវចុះ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ លើផ្ទៃដីទំហំ ៧.៨៩៦,១១ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច និងឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ តំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនបានចុះបញ្ជីដីរដ្ឋ និងធ្វើអនុប្រយោគជាដីឯកជនរបស់រដ្ឋនៅឆ្នាំ២០១៦ និងបានបញ្ចប់ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ ហើយទទួលបានការឯកភាពពីក្រសួងបរិស្ថាន តាមលិខិតលេខ ១៥៦២ ស.ជ.ណ ប.ស្ត ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ និងកិច្ចសន្យាការពារបរិស្ថាន និងសង្គម ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ក្រុមហ៊ុនហ្គ្រេនឌីស ធីមប៊ើរ អិលធីឌី ជានាទទួលខុសត្រូវ និងអនុវត្តនូវខ្លឹមសារដែលបានរៀបរាប់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ (ESIA) សម្រាប់គម្រោងដាំដើមម៉ៃសាក់ដែលក្រសួងបានឯកភាព។ ក្នុងជំពូកទី៨កម្មវិធីអង្កេតតាមដានបរិស្ថានបញ្ជាក់ថាក្រុមហ៊ុនម្ចាស់គម្រោងត្រូវធ្វើការត្រួតពិនិត្យ ឬអង្កេតតាមដានគម្រោង ដើម្បីកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមឱ្យដល់កម្រិតអប្បរមា។ កម្មវិធីអង្កេតតាមដានបរិស្ថាននេះផ្តោតសំខាន់លើ ធនធានបរិស្ថានរូបសាស្ត្រ ធនធានបរិស្ថានជីវសាស្ត្រ និងធនធានបរិស្ថានសង្គម ហើយសូចនករ សំខាន់ៗសម្រាប់ធ្វើការវាយតម្លៃផលហេតុប៉ះពាល់ និងវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម នៅក្នុងតំបន់ត្រូវបានកំណត់។

របាយការាណ៍លទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននេះ ឆ្លើយតបនឹងការតាំងចិត្ត ឬឆន្ទៈការពារបរិស្ថាន ដែលមានចែងក្នុងកិច្ចសន្យាការពារបរិស្ថាន និងសង្គម និងដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានឱ្យនៅកម្រិតអប្បរមានៅអំឡុងពេលអភិវឌ្ឍរបស់គម្រោង។ ក្នុងបាយការណ៍នេះ បានបញ្ជាក់ពីលទ្ធផលសម្រេចបានរបស់ម្ចាស់គម្រោងក្នុងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងសង្គម និងរាយការណ៍ជូននាយកដ្ឋានអង្កេត ត្រួតពិនិត្យ និងវាយតម្លៃហេតុផលប៉ះ

ពាល់បរិស្ថាន និងសង្គម នៃក្រសួងបរិស្ថានដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ណែនាំតាមបទដ្ឋានច្បាប់ បច្ចេកទេស និងការអនុវត្តជាក់ស្តែង ដើម្បីកែតម្រូវបន្ថែម។

### ១.១ គោលបំណង

ការត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន មានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ដើម្បីកំណត់ពីផលប៉ះពាល់សំខាន់ៗដែលអាចនឹងកើតមានឡើងនៅក្នុងការអនុវត្តគម្រោង
- បង្កើតកម្មវិធីការពារ កែតម្រូវ ដើម្បីកាត់បន្ថយហេតុផលប៉ះពាល់ឱ្យនៅត្រឹមកម្រិតអប្បរមា
- ដើម្បីធានាការអនុវត្តគម្រោង និងការថែទាំចម្ការឈើ អនុលោមតាមផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ដែលក្រសួងបានឯកភាព។

## ២. វិធីសាស្ត្រនៃការវាយតម្លៃ

ការអង្កេតជាក់ស្តែងនៅលើទីវាល ត្រូវបានប្រើប្រាស់ដើម្បីការកំណត់នូវហេតុផលប៉ះពាល់ជាអវិជ្ជមាន នៅតាមចន្លោះរងដាំឈើ ផ្លូវក្នុងតំបន់គម្រោង ព្រៃរក្សាទុកតាមដងអូរ ការប្រើប្រាស់ដី និងថ្នាំកសិកម្ម ការស្តុកសំណល់រឹងរាវ ទឹកបរិភោគរបស់បុគ្គលិកកម្មករ ព្រំដីបានចុះបញ្ជី ប្រភពទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋ ការិយាល័យរដ្ឋបាលក្រុមហ៊ុន ទីតាំងស្នាក់នៅរបស់បុគ្គលិក-កម្មករ ផ្លូវចេញចូលរបស់គម្រោងទាំងអស់ កន្លែងជួសជុលផ្លូវ ទីតាំងចំណតយានយន្ត និងគ្រឿងចក្រ រោងជាង ឃ្លាំង ទីតាំងកន្លែងងកំពុងធ្វើការក្នុងអនុតំបន់ទាំង២៣ ប៉មយាមភ្លើង ជាពិសេសនៅរជូវប្រាំង និងថ្នាលបណ្តុះកូនឈើ។ ការអង្កេតតាមដាន ឬ ដោយប្រើប្រាស់បញ្ជីពិនិត្យ និងផ្ទៀងផ្ទាត់ជាក់ស្តែងនៅទីវាល។ លទ្ធផលនៃការត្រួតពិនិត្យ ឬអង្កេតតាមដាន ត្រូវកត់ត្រាដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យ (Checklist) និងឆ្លើយតបប្រធានផ្នែកបច្ចេកទេសនីមួយៗដើម្បីទទួលបានជាតុចូលបន្ថែមលើវិធានការបន្ត។

## ៣. លទ្ធផលនៃវាយតម្លៃ

ការពិនិត្យជាក់ស្តែងនៅនឹងទីតាំងគម្រោង លើការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ក្នុងដំណាក់កាលប្រតិបត្តិគម្រោង ដោយផ្តោតសំខាន់លើធនធានបរិស្ថានរូបសាស្ត្រ ធនធានបរិស្ថានជីវៈសាស្ត្រ និងសេដ្ឋកិច្ចសង្គម ទទួលបានបានលទ្ធផលដូចបញ្ជាក់ក្នុងតារាងទី១ខាងក្រោម៖

*តារាងទី១៖ កម្មវិធីអង្កេតតាមដានបរិស្ថានលើគម្រោងដាំដើមម៉ៃសាក់*

| ធនធានបរិស្ថាន | ទីតាំងត្រួតពិនិត្យ | វិធីសាស្ត្រ និងប៉ារ៉ាម៉ែត្រ | លទ្ធផល |
|---|---|---|---|
| ១. ដំណាក់កាលប្រតិបត្តិគម្រោង | | | |
| ១.១ ធនធានបរិស្ថានរូបសាស្ត្រ | | | |
| សណ្ឋានដីនិងការហូរច្រោះ | ១. តាមចន្លោះរង<br>២. ផ្លូវក្នុងតំបន់គម្រោង<br>៣. ព្រៃរក្សាទុកតាមដងអូរ | ▪ ពិនិត្យសណ្ឋានដីតាមចន្លោះរងកូនឈើ<br>▪ ពិនិត្យស្ថានភាពផ្លូវក្នុងតំបន់គម្រោង<br>▪ ពិនិត្យស្ថានភាពព្រៃរក្សាទុកតាមដងអូរ | ✓ ក្រុមបានរៀបចំវិធានការបង្ការការហូរច្រោះ ដោយរៀបចំរបាំងការពារសងខាងផ្លូវ ទីតាំងដីជម្រាល និង ទីតាំងសាងសង់លូបង្ហូរទឹកនានាក្នុងសម្បទានដីសេដ្ឋកិច្ច<br>✓ ព្រៃទ្រនាប់អូរក្នុង និងក្រៅតំបន់សម្បទានដីសេដ្ឋកិច្ចត្រូវបានរក្សាទុក (១៣០៤ហិកតា ជាតំបន់រក្សាទុកបន្ថែមស្ថិតនៅក្នុងសម្បទានដីសេដ្ឋកិច្ច)<br>✓ មានករណីដីធ្លីកើតមានក្នុងតំបន់ទ្រនាប់អូរ ដែលជាបុព្វហេតុនាំឱ្យមានការបំពុលទឹក |

| | | | |
|---|---|---|---|
| | | | និងហូរច្រោះ |
| គុណភាពដី | ១.ការប្រើប្រាស់ដី និងថ្នាំកសិកម្ម<br>២.ការស្តុកសំណល់រឹង-រាវគ្រប់ប្រភេទនិងការប្រើប្រាស់គ្រឿងចក្រ | ▪ ពិនិត្យការប្រើប្រាស់ដី និងថ្នាំកសិកម្ម<br>▪ ពិនិត្យមើលទីតាំងទុកដាក់សំណល់រឹង-រាវគ្រប់ប្រភេទ និងកន្លែងទីតាំងទុកដាក់គ្រឿងចក្រ | ✓ ការប្រើប្រាស់ដី និងថ្នាំកសិកម្មទៅតាមបច្ចេកទេសដែលបានកំណត់ និងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>✓ ការទុកដាក់សំណល់រឹង-រាវត្រឹមត្រូវ និងដាច់ដោយឡែកតាមប្រភេទកាកសំណល់<br>✓ រណ្តៅទុកដាក់កាកសំណល់ត្រូវបានកំណត់ និងនៅឆ្ងាយពីប្រភពទឹក |
| **១.២ ធនធានជីវសាស្ត្រ** | | | |
| ធនធានព្រៃឈើ និងសត្វព្រៃ | ១.ព្រៃការពារតាមមាត់អូរ តំបន់ភ្នំ ទីតាំងសក្ការៈ តំបន់ដីសើម<br>២. ប៉មការពារភ្លើងឆេះព្រៃ និងកូនឈើជាពិសេសនៅរដូវប្រាំង | ▪ ត្រួតពិនិត្យលើការទន្ទ្រានកាប់ ឬចាប់ដីព្រៃ ជាកម្មសិទ្ធខុសច្បាប់តាមមាត់អូរតំបន់ភ្នំ<br>▪ ត្រួតពិនិត្យបទល្មើសព្រៃឈើ និងសត្វព្រៃ<br>▪ ពិនិត្យស្ថានភាពប៉មការពារភ្លើងឆេះព្រៃ | ✓ រក្សាទុកព្រៃតាមមាត់អូរ តំបន់ភ្នំ តំបន់សក្ការៈបូជា និងតំបន់ដីសើម<br>✓ តាមប៉ុស្តិ៍យាមនីមួយៗ សន្តិសុខត្រួតពិនិត្យ និងគ្រប់គ្រងបទល្មើសព្រៃឈើតាមរយៈប្រព័ន្ធអនុញ្ញាតិ ការល្បាត និងប្រព័ន្ធរាយការណ៍<br>✓ មានប្រជាជនក្នុង និងខាងក្រៅកាប់កូនឈើក្នុងដីសម្បទាន ដីអភិរក្ស និងដាក់អន្ទាក់ បរបាញ់សត្វ<br>✓ មានការធ្វើប៉មថ្មី មានប៉ម៤ ប៉ម៧ និងជួសជុលប៉ម៥ និងប៉ម៨ ដើម្បីមើលភ្លើងឆេះព្រៃ និងចម្ការឈើ |
| **១.៣ ធនធានសេដ្ឋកិច្ចសង្គម** | | | |
| ការប្រើប្រាស់ដី | ១.ព្រំដីដែលបានចុះបញ្ជីដោយ MLMUPC និងDLMUPC | ▪ ពិនិត្យមើលព្រំប្រទល់តំបន់គម្រោងដែលបានចុះបញ្ជីទំហំ ៧.៨៩៦,១១ហ.ត មានការបាត់បង់ដែរឬទេ<br>▪ ត្រួតពិនិត្យមើលការឈូសដី តើមានការរំលោភដីព្រៃការពារទន្ទាប់អូរឬទេ? | ✓ មានការឈូសឆាយដី និងកាប់ឆ្ការរំលោភយកដីព្រៃការពារទន្ទាប់អូរធ្វើជាកម្មសិទ្ធិឯកជន<br>✓ មានបញ្ហាដីធ្លីដែលកើតចេញពីការចុះបញ្ជីជាប្រព័ន្ធខាងស្រុកឱរ៉ាល់ និងបញ្ហាដីធ្លីដែលកើតមានស្រាប់ដែលមានសរុបរហូតដល់ទៅ ១២៩ករណី ទំហំសរុបប្រហែលជា ១៥២ ហិកតា។ បញ្ហាទាំងអស់នេះកំពុងបន្តនិតិវិធីដោះស្រាយ។<br>✓ បញ្ហាដីធ្លី និងបញ្ហាព្រំប្រទល់រវាងសម្បទានដីសេដ្ឋកិច្ច និងដីឯកជន (អនុសាសន៍ ថ្ងៃ០៣ ខែកក្កដា ឆ្នាំ២០២០)<br>✓ បោះបង្គោលព្រំសម្បទានដីសេដ្ឋកិច្ច ដោយមានការចូលរួមពីម្ចាស់ក្បាលដីឯកជន អាជ្ញាធរមូលដ្ឋាន រដ្ឋបាលព្រៃឈើ (១២៩បង្គោលព្រំបានដោះរួចនៅក្បាលដីលេខ ក៤ និងខ ២សម្រាប់ឆ្នាំ២០២១) |
| ការប្រើប្រាស់ទឹក | ១. ទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋ | ▪ ពិនិត្យស្ថានភាពប្រើប្រាស់របស់ប្រជាពលរដ្ឋ | ✓ ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋមានភាពលំបាកដោយសារនៅរដូវប្រាំងដាច់ទឹក<br>✓ ចំណុចសក្តានុពលដើម្បីជីកអណ្តូងបានកំណត់ |
| ការប្រើប្រាស់ថាមពលចំអិន | ១.ការប្រើប្រាស់ថាមពលចំអិនរបស់ប្រជាពលរដ្ឋ | ▪ ពិនិត្យមើលការប្រើប្រាស់ថាមពល | ភាគច្រើនប្រជាពលរដ្ឋប្រើប្រាស់អុសក្នុងការចំអិនម្ហូបអាហារ ហើយពួកគេកាប់ដីសម្បទាន និងក្រៅ |

| | | | |
|---|---|---|---|
| សុខភាព និងសុវត្ថិភាពសាធារណៈ | ១.ទីតាំងការិយាល័យរដ្ឋបាលក្រុមហ៊ុន<br>២.ទីតាំងស្នាក់នៅរបស់បុគ្គលិក-កម្មករ<br>៣.ផ្លូវចេញចូលរបស់គម្រោងទាំងអស់<br>៤.កន្លែងជួសជុលផ្លូវ<br>៥.ទីតាំងចំណតយានយន្តនិងគ្រឿងចក្ររោងជាង ឃ្លាំង | ▪ ការត្រួតពិនិត្យភាពហប់ក្តៅ និងមិនមានខ្យល់ចេញចូល<br>▪ ការត្រួតពិនិត្យលើការគ្រប់គ្រង និងដំណើរឧបករណ៍សុវត្ថិភាពទាំងអស់ ( ឧបករណ៍ប្រអប់សុវត្ថិភាពអគ្គិសនី បំពង់ពន្លត់អគ្គីភ័យ ប្រព័ន្ធសុវត្ថិភាពផ្តល់ដំណឹងល<br>▪ ការត្រួតពិនិត្យលើការផ្តល់ទឹកស្អាត និងអនា ម័យ<br>▪ ការត្រួតពិនិត្យលើការផ្តល់ឧបករណ៍សុវត្ថិភាពនៅពេលបំពេញការងារ<br>▪ ការត្រួតពិនិត្យលើថ្នាំពេទ្យសម្រាប់សង្គ្រោះ បឋម និងសម្រាប់បន្សាបពិសនានា | ✓ មានខ្យល់ចេញ-ចូល ( កង្ហារ និងម៉ាស៊ីនត្រជាក់ )<br>✓ ឧបការណ៍សុវត្ថិភាពទាំងអស់មានការត្រួតពិនិត្យតាមដានត្រឹមត្រូវ ( បំពង់ពន្លត់អគ្គីភ័យចំនួន ៤៦បំពង់ បំពាក់នៅស្ថានីយប្រេង រោងម៉ាស៊ីនភ្លើង ចង្រ្កាន ការិយាល័យ ផ្ទះបុគ្គលិក និងទីតាំងសំខាន់ៗ មួយចំនួនទៀត ( ផែនទី )<br>✓ បុគ្គលិកត្រូវបានបណ្តុះបណ្តាល )<br>✓ មានបុគ្គលិកថែទាំបានស្អាត និងអានាម័យ<br>✓ មានការថែទាំតាមបច្ចេកទេស និងពេលមានបញ្ហារាយកាណ៍ជូនអ្នកគ្រប់គ្រង<br>✓ មានថ្នាំពេទ្យក្នុងការសង្រ្គោះបឋម បើអ្នកជម្ងឺធ្ងន់ធ្ងរបញ្ជូនទៅពេទ្យធំ |
| ចរាចរណ៍ | ១.ផ្លូវមេរបស់គម្រោង<br>២.ផ្លាកសញ្ញាចរាចរតាមផ្លូវចេញចូលនានាក្នុងតំបន់គម្រោង | ▪ ការត្រួតពិនិត្យលើការដឹកជញ្ជូនល្បឿនបើកបរ ផ្លូវគោក និងការរាំងស្ទះ<br>▪ ការត្រួតពិនិត្យលើការរលំឬបាក់មែកឈើតាមផ្លូវនានា<br>▪ ការត្រួតពិនិត្យលើការដាក់ស្លាកសញ្ញាចរាចរណ៍តាមដងផ្លូវនានា | ✓ ត្រួតពិនិត្យរាល់ការដឹកជញ្ជូនតាមប៉ុស្តិ៍យាមនីមួយៗ<br>✓ ត្រួតពិនិត្យរាល់បញ្ហាដើមឈើបាក់មកលើផ្លូវនានា<br>✓ មានសញ្ញាណចរាចរណ៍ដាក់សម្គាល់តាមប៉ារ៉ាស់យាមនីមួយៗ |
| ផ្លូវគមនាគមន៍ | ១.ស្ថានភាពផ្លូវទាំងអស់របស់គម្រោងទីតាំងតាមផ្លូវចេញចូលនានាក្នុងតំបន់គម្រោង | ▪ ពិនិត្យលើការខូចខាត និងជួសជុល<br>▪ ការត្រួតពិនិត្យស្ថានភាពផ្លូវ<br>▪ ពិនិត្យការថែទាំជួសជុលផ្លូវក្នុងតំបន់គម្រោង | ✓ មានការជួសជុលក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចប្រវែង១៧គម<br>✓ មានការត្រួតពិនិត្យផ្លូវក្នុងដីសម្បទាន<br>✓ មានការជួសជុល និងថែទាំផ្លូវភ្លើង ផ្លូវនានាក្នុងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន<br>✓ សម្រាប់ឆ្នាំនេះ ផ្លូវមានបញ្ហាហូរច្រោះ និងដាច់ខ្លាំងដោយសារទឹកភ្លៀង។<br>✓ បានធ្វើការដាក់មែកឈើជាសញ្ញាប្រាប់អ្នកធ្វើដំណើរឆ្លងកាត់ទាំងអស់ឱ្យមានការប្រុងប្រយ័ត្ន ជៀសវាសគ្រោះថ្នាក់ ម្យ៉ាងវិញទៀតវាជួយកាត់បន្ថយការហូរច្រោះផងដែរ។ |
| ហានិភ័យ | ១.ទីតាំងការិយាល័យរដ្ឋបាលក្រុមហ៊ុន<br>២.កន្លែងងស្នាក់នៅបុគ្គលិក -កម្មករ<br>៣.ចំណតយានយន្ត និងគ្រឿងចក្ររោងជាង ឃ្លាំង<br>៤.ទីតាំងកន្លែងងកំពុងធ្វើការក្នុងអនុតំបន់ទាំង២៣<br>៥. ប៉មការពារយាមភ្លើងនិងកូនឈើជាពិសេសនៅរដូវប្រាំង | ▪ ពិនិត្យកន្លែងទីតាំងស្តុកប្រេងឥន្ទនៈ និងសំណល់ប្រេង<br>▪ ពិនិត្យលើការគ្រប់គ្រង និងដំណើរឧបករណ៍សុវត្ថិភាព ទាំងអស់ ( ឧបករណ៍ប្រអប់សុវត្ថិភាពអគ្គិសនី បំពង់ពន្លត់អគ្គីភ័យ ប្រព័ន្ធសុវត្ថិភាពផ្តល់ដំណឹងកណ្តឹង ។ល។ | ✓ មានការទុកដាក់ និងរៀបចំបានល្អ និងសំណល់ទុកដាក់តាមប្រភេទរបស់វា<br>✓ ឧបការណ៍សុវត្ថិភាពទាំងអស់មានការត្រួតពិនិត្យតាមដានត្រឹមត្រូវ ទៅតាមបច្ចេកទេស<br>✓ ក្រៅតែពីបញ្ហាដែលបានរៀបរាប់ហើយ ក៏មានបញ្ហាដែលបណ្តាលមកពីបាតុភូតធម្មជាតិដូចជាខ្យល់កន្រ្ទាក់ ដែលធ្វើឱ្យមានការខូចខាតដំបូលការិយាល័យ បាក់ដើមឈើ ជាដើម។<br>✓ លើសពីនេះទៀតក៏មានបញ្ហាបាត់បង់ |

| | | | |
|---|---|---|---|
| | | | និងខូចខាតសម្ភារៈដោយសារការលបលួចពីសំណាក់ជនមិនស្គាល់មុខ។ |

## ៤. ការគំរាមកំហែង និងដំណោះស្រាយ

លទ្ធផលនៃការវាយតម្លៃនៅលើទីវាល (តារាងទី១) ក្រុមហ៊ុនហ្គ្រែនឌីស ធីមបើរ អិលធីឌី បានអនុវត្តគម្រោងវិនិយោគ ដោយយកចិត្តទុកដាក់លើការការពារបរិស្ថាន និងសង្គម ក្រុមហ៊ុននូវមានចំណុចខ្វះខាតបន្តិចបន្តួចបានរកឃើញក្នុងពេលធ្វើការវាយតម្លៃដែលនឹងត្រូវធ្វើការកែតម្រូវដោយអនុឡោមតាមសូចនករ ដូចបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។ តារាងខាងក្រោមបង្ហាញពីចំណុចខ្វះខាត និងវិធានការរយៈពេលខ្លី និងរយៈពេលវែង (តារាងទី២)។

*តារាងទី២៖ ការគំរាមកំហែង និងដំណោះស្រាយលើផលប៉ះពាល់បរិស្ថាន*

| ល.រ | កត្តាគំរាមកំហែងបរិស្ថាន | លទ្ធភាពក្នុងការដោះស្រាយ | |
|---|---|---|---|
| | | រយៈពេលខ្លី | រយៈពេលវែង |
| ១ | តំបន់ការពារប្រភពទឹកត្រូវភ្លើងឆេះដែលបង្កការរាំងស្ទះយ៉ាងខ្លាំងដល់ការដុះលូតលាស់កូនឈើដោយធម្មជាតិ | • ពង្រឹងក្រុមល្បាតការពារភ្លើងឆេះព្រៃ<br>• បន្តផ្សព្វផ្សាយដល់សហគមន៍<br>• បង្កើនទំនាក់ទំនងជាមួយសហគមន៍មូលដ្ឋាន<br>• ដាំឈើធម្មជាតិស្តារបន្ថែមតាមតំបន់មាត់អូរ<br>• ដាក់ផ្លាកនៅតាមទីតាំងទ្រនាប់អូរដែលបានដាំស្តារកូនឈើធម្មជាតិរួចរាល់ | • រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ស្តារព្រៃឈើឡើងវិញតាមរយៈការជំរុញដំណុះធម្មជាតិនិងការដាំបន្ថែមនៅតំបន់រិចរឹលខ្លាំង<br>• ការពារភ្លើងឆេះព្រៃ |
| ២ | ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋមានភាពលំបាកដោយសារនៅរដូវប្រាំងដាច់ទឹក | • រក្សាព្រៃតាមមាត់អូរ និងតំបន់ជុំវិញដើម្បីការពារការហូរច្រោះ<br>• កំណត់តំបន់សក្តានុពលសម្រាប់ជីកអណ្តូង ស្រះទឹក<br>• រក្សាទុកថ្លុក តំបន់ដីសើម ឬអន្លង់នានាតាមអូរធម្មជាតិ<br>• ធ្វើការស្តារអូរដែលរាក់ដោយមិនមានការផ្លាស់ប្តូរខ្សែទឹកធម្មជាតិ។ | • ពិនិត្យលើលទ្ធភាពនៃការជីក អណ្តូង ឬស្រះទឹក សម្រាប់ប្រជាជនមូលដ្ឋាន<br>• រៀបចំទំនប់បង្ហៀរទឹក ដើម្បីរក្សាទឹកសម្រាប់ប្រជាជនប្រើប្រាស់ និងជួយបង្កើនធនធានមច្ឆាជាតិក្នុងតំបន់ |
| ៣ | មានករណីដីធ្លីកើតមានក្នុងតំបន់ទ្រនាប់អូរដែលជាបុព្វហេតុនាំឱ្យមានការបំពុលទឹក និងហូរច្រោះ | • ប្រជុំដោះស្រាយ សម្របសម្រួលដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន រដ្ឋបាលព្រៃឈើ<br>• កំណត់ព្រំតំបន់ទ្រនាប់អូរ និងបោះបង្គោលព្រំ (ពណ៌ក្រហម)<br>• ផ្សព្វផ្សាយដល់ប្រជាជនពីសារៈសំខាន់នៃកិច្ចការពារប្រភពទឹក | • ដាំស្តារព្រៃឡើងវិញនៅតាមព្រៃការពារ និងព្រៃទ្រនាប់អូរ<br>• បន្តផ្សព្វផ្សាយដល់ប្រជាជនពីសារៈសំខាន់នៃកិច្ចការពារប្រភពទឹក<br>• បន្តការដោះស្រាយ សម្របសម្រួលដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន រដ្ឋបាលព្រៃឈើ និងស្ថាប័នពាក់ព័ន្ធនានា |
| ៤ | បញ្ហាដីធ្លី និងបញ្ហាព្រំប្រទល់រវាងសម្បទានដីសេដ្ឋកិច្ចនិងដីឯកជនតាមរយៈការចុះបញ្ជីរជាប្រព័ន្ធខាងស្រុកឱរ៉ាល់កាលឆ្នាំ ២០១៩កន្លងទៅ និងតាមអនុសាសន៍ ថ្ងៃ០៣ ខែកក្កដា ឆ្នាំ២០២០ | • បោះបង្គោលព្រំប្រទល់រវាងសម្បទានដីសេដ្ឋកិច្ច និងដីឯកជន<br>• ប្រជុំដោះស្រាយ សម្របសម្រួលដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន រដ្ឋបាលព្រៃឈើ<br>• ជំរុញការដាំដុះនៅតំបន់មានសក្តានុពលបញ្ហាដីធ្លី | • បោះបង្គោលព្រំប្រទល់រវាងសម្បទានដីសេដ្ឋកិច្ច និងដីឯកជន<br>• ប្រជុំដោះស្រាយ សម្របសម្រួលដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន រដ្ឋបាលព្រៃឈើ<br>• ជំរុញការដាំដុះនៅតំបន់មានសក្តានុពលបញ្ហាដីធ្លី |

## ៥. បញ្ហាប្រឈម

ក្រៅតែពីបញ្ហាគំរាមកំហែងបរិស្ថានខាងលើ ក្រុមហ៊ុនបានជួបនៅបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ផ្អាកការដាំដុះ និងការងារប្រតិបត្តិការចម្ការឈើស្ទើរតែទាំងអស់នៅក្នុងឆ្នាំ២០២១ ដោយសារមានវិបត្តិកូវីដ១៩ ក្នុងព្រឹត្តិការណ៍ឆ្លងចូលសហគមន៍កាលពីខែកុម្ភៈ ២០២១
- មានការយឺតយ៉ាវក្នុងការជួសជុលថែទាំផ្លូវរបស់គម្រោងដោយសារតែមានការខ្វះខាតកំលាំងបុគ្គលិក កម្មករ
- មានការលួចកាប់ គាស់ឈើប្រណិតនៅតាមតំបន់ការពារប្រេកពទឹក
- មានការបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានរួមដូចជា៖ ទ្វាររបង, កូនឈើពាណិជ្ជកម្ម, ផ្លាកពិដារ និងកាត់ស្លាក់ការពាររន្ទះជាដើម។
- មានបញ្ហាងាប់គោមួយចំនួនដោយសារតែការរីករាលដាលនៃជំងឺដុំពកដែលផ្ទុះឡើងលើសត្វគោ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើសូម **លោកប្រធាននាយកដ្ឋាន** មេត្តាជ្រាបជារបាយការណ៍ និងមានអនុសាសន៍ណែនាំដោយក្តីអនុគ្រោះ។

ថ្ងៃ ចន្ទ ៨ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៧...ខែ......ធ្នូ......ឆ្នាំ២០២១

ប្រធានប្រតិបត្តិ



ផ្ទះលេខ ៣៨ដេ, ផ្លូវ៤៩៤, សង្កាត់ផ្សារដើមថ្កូវ,
ខណ្ឌចម្ការមន, ភ្នំពេញ, កម្ពុជា
ទូរស័ព្ទ: +(៨៥៥) ២៣ ២២២ ១៧៣
សារអេឡិចត្រូនិច: info@grandistimber.com

38D, Street 494, Sangkat Phsar Doeum Thkov,
Khan Chamkarmorn, Phnom Penh, CAMBODIA
Telephone: +(855) 23 222 173
Email: info@grandistimber.com

FSC
www.fsc.org
FSC™ C109614
The mark of responsible forestry